# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 463

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : សិក្ខាសាលាស្តីពីការបង្កើតកំណើន និង ការងារ តាមរយៈ សហគមន៍ សេដ្ឋកិច្ច អាស៊ាន៖ កាលានុវត្តភាព និងយុទ្ធសាស្ត្រ

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 02/01/18

កាលបរិច្ឆេទបញ្ចប់គម្រោង 29/12/18

៣. ចំណាយគម្រោងសរុប $176,500

៤. ស្ថាប័នទទួលខុសត្រូវ ទីស្តីការគណៈរដ្ឋមន្ត្រី

RESPONSIBLE UNIT

អង្គភាពទទួលខុសត្រូវ

៥. ស្ថានភាពគម្រោង គម្រោងដែលបានលុបចោល

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ បញ្ចូលគ្នារវាងថវិការ និងឥណទានផ្សេងៗ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងដែលបានស្នើឡើងនេះ នឹងគូសបញ្ជាក់ពីជាតុផ្សំគន្លឹះ បញ្ហាប្រឈម និងកាលានុវត្តភាពរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ខណៈដែលសហគមន៍អាស៊ានទាំងមូល ទើបត្រូវបានបង្កើតឡើងជាស្ថាពរនាចុងឆ្នាំ២០១៥។ ក្នុងនាមជាប្រទេសសមាជិកអាស៊ាន កម្ពុជាមានកាតព្វកិច្ចបញ្ជ្រាបព័ត៌មានពីសហគមន៍អាស៊ាននេះ ជូនចំពោះប្រជាពលរដ្ឋខ្លួន ជាពិសេសពត៌មានពាក់ព័ន្ធនឹងសហគមន៍សេដ្ឋកិច្ចអាស៊ាន។ ដូច្នេះ គម្រោងស្នើនេះនឹងលើកកម្ពស់ការយល់ដឹងរបស់អ្នកចូលរួម ក៏ដូចជាបង្កើតនូវយុទ្ធសាស្ត្រសំខាន់នានា ក្នុងការទាញយកអត្ថប្រយោជន៍ពីសមាហរណកម្មតំបន់នេះ ដែលជាលទ្ធផលនឹងចូលរួមពង្រឹង និងលើកកម្ពស់ចំណេះដឹងរបស់អ្នកចូលរួមជាពិសេស និងសាធារណជនទូទៅដែលមានចំណាប់អារម្មណ៍លើអាស៊ាន។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

អភិបាលកិច្ច និងរដ្ឋបាល Governance and Administration

១២. ទីតាំងអនុវត្តគម្រោង ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

ស្វាយរៀង, រាជធានីភ្នំពេញ, សៀមរាប, កំពង់ចាម,

១៣. គោលបំណងរបស់គម្រោង ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

គម្រោងស្នើនេះមានគោលបំណងសម្រេចឱ្យបាននូវ: (១) ការបង្កើនចំណេះដឹងរបស់អ្នកចូលរួម តាមរយៈការចែករំលែកនូវព័ត៌មាន និងកាលានុវត្តភាពនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និង (២) រិះរកយុទ្ធសាស្ត្រដើម្បីជានាថាភាគីពាក់ព័ន្ធ ជាពិសេសវិស័យឯកជននៅកម្ពុជា យល់ច្បាស់ពីដំណើរការសមាហរណកម្មសេដ្ឋកិច្ចអាស៊ាននេះ។

១៤. ការពិពណ៌នាអំពីគម្រោង ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

គម្រោងស្នើនេះ ជាគម្រោងសម្រាប់ឆ្នាំ២០១៧ និងជាគម្រោងមួយក្នុងចំណោមគម្រោងដទៃទៀត សម្រាប់អនុវត្តក្នុងឆ្នាំ២០១៨ និង២០១៩។ គម្រោងនេះ ត្រូវបានគ្រោងឡើងសម្រាប់អនុវត្តក្នុងតំបន់បួនកន្លែង៖ រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តកំពង់ចាម និងខេត្តស្វាយរៀង សម្រប់តំបន់ផ្សេងៗទៀតក្រៅពីតំបន់ទាំងបួន នឹងមានសកម្មភាពស្នើ ក៏ដូចជាអនុវត្តនាឆ្នាំបន្ទាប់ទៀត (ឆ្នាំ២០១៨ និង២០១៩)។

ដូចបញ្ជាក់ក្នុងកម្មវត្ថុ គម្រោងស្នើនេះជាវិធីមួយ សំដៅដល់ការលើកកម្ពស់ការយល់ដឹងស្តីពីអាស៊ានជាទូទៅ និងការយល់ដឹងពីធាតុផ្សំគន្លឹះ បញ្ហាប្រឈម និងកាលានុវត្តភាពនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ានជាពិសេស។ លើសពីនេះទៀត យុទ្ធសាស្ត្រដើម្បីទាញយកអត្ថប្រយោជន៍ពីសហគមន៍សេដ្ឋកិច្ចអាស៊ាន នឹងត្រូវបានធ្វើបទបង្ហាញផងដែរ។

១៥. យុត្តិកម្មលើគម្រោង ( បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស )

ជាបឋម ដោយសារថាកម្ពុជាជាប្រទេសសមាជិកអាស៊ាន ហើយសហគមន៍អាស៊ានទើបបានបង្កើតជាស្ថាពរនាចុងឆ្នាំ២០១៥កន្លងទៅនេះ ដូច្នេះវាចាំបាច់ណាស់ក្នុងការចែករំលែក និងផ្សព្វផ្សាយពីធាតុផ្សំគន្លឹះ បញ្ហាប្រឈម និងកាលានុវត្តភាពនៃសហគមន៍អាស៊ាននេះ ជាពិសេសសហគមន៍សេដ្ឋកិច្ចអាស៊ាន។ ការបង្កើនការយល់ដឹង ស្តីពីសហគមន៍សេដ្ឋកិច្ចអាស៊ាន ផ្តល់នូវសារៈសំខាន់ឱ្យបណ្តាភាគីពាក់ព័ន្ធ អាចត្រៀមលក្ខណៈ និងទាញយកអត្ថប្រយោជន៍ពីសហគមន៍នេះ។

ទីពីរ គម្រោងស្នើនេះរួមមានសមាសភាព ដូចជាវាគ្មិន/អ្នកជំនាញមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ជាអាទិ៍ តំណាងមកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាភាគីពាក់ព័ន្ធនឹងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងតំបន់សេដ្ឋកិច្ចពិសេស នឹងត្រូវបានអញ្ជើញឱ្យចូលរួម ដើម្បីចែករំលែកការយល់ដឹង ការអនុវត្តន៍ល្អៗ និងបញ្ហាប្រឈមពាក់ព័ន្ធនឹងសហគមន៍សេដ្ឋកិច្ចអាស៊ាន។

ជាចុងបញ្ចប់ របាយការណ៍សង្ខេបនឹងត្រូវបានចងក្រងនិងផ្សព្វផ្សាយ ទាំងជាភាសាខ្មែរនិងអង់គ្លេស។

១៦. ផលប្រយោជន៍របស់គម្រោង ( រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង )

គម្រោងស្នើនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ស្ថាប័ន/ភាគីពាក់ព័ន្ធ រួមទាំងវិស័យសាធារណៈនិងឯកជន ជាពិសេស អ្នកចូលរួមដែលមកពីតំបន់ទាំងបួននៃប្រទេសកម្ពុជា (រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តកំពង់ចាម និងខេត្តស្វាយរៀង)។ ជាក់ស្តែង អ្នកទទួលផលផ្ទាល់ជាអ្នកចូលរួម វាគ្មិន និងបុគ្គលដែលពាក់ព័ន្ធនឹងគម្រោងនេះ។ គម្រោងនេះផងដែរនឹងផ្តល់អត្ថប្រយោជន៍ដោយប្រយោលដល់បុគ្គល និងអង្គភាពដែលមានចំណាប់អារម្មណ៍លើសហគមន៍សេដ្ឋកិច្ចអាស៊ាន។ បន្ថែមពីលើនេះ គម្រោងនេះនឹងរួមចំណែក ដល់កំណើនជាតិ តាមរយៈការអនុវត្តនូវចំណេះដឹងនិងមេរៀនទទួលបានពីសិក្ខាសាលានេះ ហើយប្រទេសសមាជិកអាស៊ានដទៃទៀត អាចទទួលបានអត្ថប្រយោជន៍ពីលទ្ធផលនៃរបាយការណ៍របស់គម្រោងនេះដោយប្រយោលផងដែរ។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | **គ្មាន** |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **មិនទាន់ចាប់ផ្តើម** |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌នាសង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស (ចំណុច ៦.១) ជាកត្តាអាទិភាពដែលគម្រោងនេះផ្តោតលើ។ គម្រោងនេះសំដៅដល់ការកសាងសមត្ថភាព ដែលនេះមិនត្រឹមតែចូលរួមកាត់បន្ថយភាពក្រីក្រ តែថែមទាំងរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិផងដែរ ជាអាទិ៍ តាមរយៈការលើកកម្ពស់ការយល់ដឹងពីជាតុផ្សំ បញ្ចូប្រភព និងកាលានុវត្តភាពនៃសហគមន៍សេដ្ឋកិច្ចអាស៊ានក្រោយឆ្នាំ២០១៥ និងការស្វែងយល់ពីយុទ្ធសាស្ត្រដើម្បីទទួលបានអត្ថប្រយោជន៍ពីសមាហរណកម្មនេះ។

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែល ទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| | | |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

| | |
|---|---|
| តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? | **គ្មាន** |

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

គម្រោងស្នើនេះ បានគិតគូពីសារសំខាន់នៃសមភាពយេនឌ័រ ដែលវិស័យអាទិភាពមួយនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ដែលជាលទ្ធផល សមភាពយេនឌ័រនឹងត្រូវបានអនុវត្តនៅពេលជ្រើសរើសអ្នកចូលរួម ដើម្បីធានាឱ្យបាននូវតុល្យភាពរវាងស្ត្រីនិងបុរស។

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

២៣. [illegible] បង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាល
ឲ្យ[illegible]អាស៊ាន ដែលគម្រោងទាំងនោះស្ទើ ទ្បើងដោយស្ថាប័ន
និងអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី។ ផ្អែកលើបទពិសោធន៍ជាច្រើនឆ្នាំ នាយកដ្ឋានមានសមត្ថភាពនិងបទពិសោធន៍គ្រប់គ្រាន់ក្នុងការលើក សម្របសម្រួល និងអនុវត្តគម្រោងនានា ជាពិសេសគម្រោងថ្នាក់តំបន់។

មិនមាន

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

គម្រោងនេះនឹងស្វែងរកមូលនិធិពីប្រភពជំនួយមួយចំនួន ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី (ADB), អង្គការ JICA និងអង្គការ GIZ។ល។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2017 | | 2018 | 2019 | 2020 | 2021 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2019-2021 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 176.5 | 0.0 | 0.0 | 176.5 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទិញសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 176.5 | 0.0 | 0.0 | 176.5 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 176.5 | 0.0 | 0.0 | 176.5 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2017 | | 2018 | 2019 | 2020 | 2021 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2019-2021 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 176.5 | 0.0 | 0.0 | 176.5 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: